# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)

# គម្រោងបញ្ចប់ផែនការ

# កំណែលើកទី៩

# ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦


**សេចក្តីសង្ខេប**......1

I. **សេចក្តីផ្តើម**......3

II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស**......5

III. **ផែនការបញ្ចប់ការស៊ើបអង្កេត**......7

IV. **ផែនការបញ្ចប់សវនាការ**......12

**ក. សំណុំរឿង០០២/០២**......12

**ខ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុក្នុងសំណុំរឿង០០២**......14

**គ. សំណុំរឿង០០៣ និង សំណុំរឿង០០៤**......14

V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ**......14

**ក. សំណុំរឿង០០២/០១**......15

**ខ. សំណុំរឿង ០០២/០២**......16

**គ. សំណុំរឿង ០០៣ និង សំណុំរឿង ០០៤**......17

VI. **សេចក្តីសន្និដ្ឋាន**......17


ឧបសម្ព័ន្ធ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមបញ្ចូលគ្រោងការសំខាន់ៗ។

**កំណត់សម្គាល់សម្រាប់អ្នកអាន៖**

គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានកែប្រែប្រចាំត្រីមាសដើម្បីគោលបំណងរៀបចំផែនការ។ វាមានការប៉ាន់ស្មានដែលល្អបំផុតដែលអាចមានសម្រាប់ការព្យាករណ៍តារាងកំណត់ពេលវេលា ក្នុងរឿងក្តីនៅចំពោះមុខ អ.វ.ត.ក. នៅពេលធ្វើកំណែ។ កត្តាមួយចំនួនរួមមានការវិវឌ្ឍន៍នៃកិច្ចនីតិវិធីតុលាការ អាចប៉ះពាល់ការព្យាករណ៍ទាំងនេះ។ ដូច្នេះតារាងកំណត់ពេលវេលានេះមិនឆ្លុះបញ្ចាំងលក្ខខណ្ឌតម្រូវផ្នែកលក្ខន្តិកៈ ទៅលើថាតើពេលណាគ្រោងការសំខាន់ៗនឹងសម្រេចបាននោះទេ។

## សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានរៀបចំឡើងដំបូងនៅខែមីនា ឆ្នាំ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាបច្ចុប្បន្នភាពប្រចាំត្រីមាសទី៩ នៃគម្រោងបញ្ចប់ផែនការដែលផុតនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦។

ក្នុងអំឡុងពេលត្រីមាសទីពីរ អង្គជំនុំជម្រះតុលាការកំពូលបានបន្តពិភាក្សាសម្រេច និងធ្វើសេចក្តីព្រាងសាលដីកាក្នុងសំណុំរឿង ០០២/០១ ដែលគ្រោងប្រកាសក្នុងត្រីមាសទីបី ឆ្នាំ២០១៦។

នៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ សវនាការលើភ័ស្តុតាងបានរីកចម្រើនទៅមុខ ជាមួយនឹងប្រធានបទសវនាការទីបួន ពោលគឺ មន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ដោយរួមបញ្ចូលបទចោទអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ មិនមានការផ្លាស់ប្ដូរទៅលើតារាងកំណត់ពេលវេលានៃការជំនុំជម្រះត្រូវបានប្រមើលទុកជាមុននោះទេ នៅក្នុងបច្ចុប្បន្នភាពនៃគម្រោងបញ្ចប់ផែនការនេះ។

ការវិវឌ្ឍក្នុងសំណុំរឿង ០០៣, ០០៤ និង ០០៤/០១ បានតម្រូវឱ្យបន្ថែមពេលវេលាលើតារាងកំណត់ពេលវេលាដែលបានព្យាករនេះ ទាក់ទងនឹងជនត្រូវចោទ មាស មុត, អ៊ោ អាន, យឹម ទិត្យ និង អ៊ឹម ចែម។ ការណ៍នេះត្រូវបានពន្យល់បន្ថែមទៀតក្នុងជំពូក II ខាងក្រោម។

ការពិពណ៌នាអំពីគម្រោងបញ្ចប់ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពនៃកិច្ចដំណើការនីតិវិធីតុលាការគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦។

## I. សេចក្តីផ្តើម

១. អង្គជំនុំជ្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរការពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អាណត្តិនៃអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[1]។

២. គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយ អ.វ.ត.ក. ក្នុងបរិបទនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់ អ.វ.ត.ក. ឱ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ[2]។ ឯកសារនេះធ្វើឡើងដោយ អ.វ.ត.ក. ដោយមានការពិគ្រោះយោបល់តាមរយៈ ការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អ.វ.ត.ក. គិតទុកជាមុនថា នៅពេលខាងមុខ ខ្លួននឹងធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី៩ ប្រចាំត្រីមាសនៃគម្រោងបញ្ចប់ផែនការ ហើយបានបញ្ចូលនូវការកែតម្រូវដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការ ដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦។

៣. ឯកសារនេះផ្តោតជាពិសេសលើការវិវត្តនាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងទាំងបី ដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និងផ្តល់នូវព័ត៌មានអំពីស្ថានភាពនៃរឿងក្តីទាំងនោះ ព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខ អ.វ.ត.ក. អាចនឹងបញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថា នឹងមិនមានសំណុំរឿងបន្ថែមទៀត បន្ទាប់ពីសំណុំរឿង ០០៣ និង ០០៤ នោះឡើយ[3]។ ដូច្នេះ បន្ទុករឿងក្តីបច្ចុប្បន្នគឺជាសំណុំរឿងសរុបដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវដោះស្រាយ។

៤. មកដល់ពេលនេះ សំណុំរឿង ០០២ ត្រូវបានបំបែកបទចោទទៅជាសវនាការតូចៗចំនួនពីរ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយ ដែលអង្គជំនុំជម្រះវិសាមញ្ញកំណត់ឈ្មោះសំណុំរឿងថា សំណុំរឿង០០២/០១ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ ជនជាប់ចោទពីរនាក់ទៀតនៅក្នុងរឿងក្តី គឺ អៀង សារី បានទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ និង អៀង ធីរិទ្ធ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ហេតុនេះហើយ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេ

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[2] នៅក្នុងសេចក្តីសម្រេចដដែលនោះ មហាសន្និបាត អ.ស.ប. បានស្នើឲ្យមាន “ការពិនិត្យយ៉ាងម៉ត់ចត់ទៅលើការផ្តល់ហិរញ្ញប្បទានសម្រាប់ អ.វ.ត.ក នៅពេលអនាគតសម្រាប់ឆ្នាំ ២០១៥ និងឆ្នាំខាងមុខទៀត”។ សូមមើលសេចក្តីសម្រេចលេខ A/RES/68/247B ដែលអនុម័តដោយមហាសន្និបាត អ.ស.ប. នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៤៖ “កម្មវត្ថុពិសេសនានាទាក់ទិននឹងថវិកាសម្រាប់កម្មវិធីរយៈពេល២ឆ្នាំម្តង ២០១៤-២០១៥” ខ, I, កថាខណ្ឌទី៨។

[3] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី - ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int Co Prosecutor 8 Sep_2009_(Eng).pdf)។ សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងចំនួនរឿងក្តីរបស់ អ.វ.ត.ក. ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

ត្រូវបានរំលត់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបានផ្តន្ទាទោសម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ទាំង នួន ជា និង ខៀវ សំផន បានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០១។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាក៏បានដាក់បណ្ដឹងសាទុក្ខកម្រិតត្រឹមតែស្នើសុំ សេចក្តីប្រកាសជាប្រយោជន៍ទៅលើការអនុវត្តទម្រង់ទូលាយបំផុតនៃសហឧក្រិដ្ឋកម្មរួមដែលហៅថា “JCE III” ជាទម្រង់ទទួលខុសត្រូវមួយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។

ដំណើរការនីតិវិធីបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ កំពុងតែបន្ត។ អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការបណ្ដឹងសាទុក្ខដំបូងរបស់ខ្លួននៅថ្ងៃទី២, ៣ និង ៦ ខែកក្កដា ឆ្នាំ២០១៥ ហើយសវនាការបណ្ដឹងសារទុក្ខបន្ថែមទៀតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ហើយសវនាការបណ្ដឹងសាទុក្ខចុងក្រោយ គ្រោងធ្វើនៅចន្លោះថ្ងៃទី១៦ ដល់ ១៨ ខែកុម្ភៈ ឆ្នាំ២០១៦។

៦. ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលអង្គជំនុំជម្រះវិសាមញ្ញដាក់ឈ្មោះថាសំណុំរឿង ០០២/០២ ផ្តោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទទាំងពីរនាក់ដែលនៅសល់។ បទចោទទាំងនោះរួមមាន អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម លើប្រធានបទនានា ដែលរួមមានការប្រព្រឹត្តិលើជនជាតិចាម ជនជាតិវៀតណាម និងពុទ្ធសាសនិក ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មន្ទីរសន្តិសុខ និងការដ្ឋាននិងសហករណ៍។ សវនាការលើភ័ស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ហើយនៅត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មសាក្សីចំនួន ៨៦ នាក់ ដើមបណ្តឹងរដ្ឋប្បវេណី ៤១ នាក់ និងអ្នកជំនាញ ៣ នាក់។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រូវបានស្តាប់សក្ខីកម្មទាក់ទងនឹងមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង។

៧. បច្ចុប្បន្ន សំណុំរឿង ០០៣ និង ០០៤ កំពុងតែស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែស៊ើបអង្កេតយ៉ាងសកម្មទៅលើសំណុំរឿងទាំងនេះ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ជនត្រូវចោទ ៤ នាក់។ រឿងក្តីប្រឆាំងនឹង អ៊ឹម ចែម ត្រូវបានបំបែកជាសំណុំរឿង ០០៤/០១ នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦។

៨. ផ្អែកតាមការវិវត្តក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញកំណត់គ្រោងការសំខាន់ចំនួន ១២ ដែលនៅសល់ សម្រាប់សំណុំរឿងចំនួនបី ដែលអង្គជំនុំជម្រះនានាបានទទួល។ គ្រោងការសំខាន់ៗដែលនៅសល់នៅក្នុងសំណុំរឿង០០២[4] និងការព្យាករណ៍ដែលបន្តពាក់ព័ន្ធគឺ៖

(i) ការចេញសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ (ត្រីមាសទី៣ ឆ្នាំ២០១៦)

(ii) ការបញ្ចប់សវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី៤ ឆ្នាំ២០១៦)

(iii) សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី១ ឆ្នាំ២០១៧)

(iv) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី៤ ឆ្នាំ២០១៧)

(v) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី១ ឆ្នាំ២០១៨) និង

[4] នៅក្នុងករណីដែលសំណុំរឿង០០២ ត្រូវបានបំបែកបន្ថែមទៀតតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទៅលើវិសាលភាពនៃសំណុំរឿង០០២/០២ ដែលរំពឹងថានឹងចេញនៅខែមេសា ឆ្នាំ២០១៤ វានឹងតម្រូវឲ្យមានសំណុំរឿង០០២/០៣។

(vi) ការចេញសាលដីកានៅក្នុងសំណុំរឿង០០២/០២ ប្រសិនបើមាន (ត្រីមាសទី៣ ឆ្នាំ២០១៩)។

៩. នៅក្នុងសំណុំរឿង ០០៣ និង ០០៤/០១ គ្រោងការដាច់ដោយឡែក ត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលនៅសេសសល់ ហើយក្នុងករណីមានការចោទប្រកាន់នោះ នឹងមានគ្រោងការបន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះ និងបណ្តឹងសាទុក្ខ[5]។ គ្រោងការសំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលបន្តនៅសេសសល់គឺ៖

(vii) សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ (ត្រីមាសទី៤ ឆ្នាំ២០១៦)

(xiii) សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ (ត្រីមាសទី៤ ឆ្នាំ២០១៦ និងត្រីមាសទី១ ឆ្នាំ២០១៧)

(ix) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ជាមួយនឹងសេចក្តីសម្រេចថាតើបញ្ជូនរឿងទៅជំនុំជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី២ ឆ្នាំ២០១៧)

(x) ការចេញដីកាដំណោះស្រាយ ក្នុងសំណុំរឿង០០៤ និង ០០៤/០១ ជាមួយនឹងសេចក្តីសម្រេចថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី (នៅត្រីមាសទី១ ឆ្នាំ២០១៧ សម្រាប់សំណុំរឿង ០០៤/០២ និងត្រីមាសទី២ និង៣ ឆ្នាំ២០១៧ សម្រាប់សំណុំរឿង ០០៤)

(xi) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី៤ ឆ្នាំ២០១៧) និង

(xii) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ណាមួយ ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង០០៤ និង ០០៤/០១ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី៣ ឆ្នាំ២០១៧ សម្រាប់សំណុំរឿង ០០៤/០១ និងត្រីមាសទី១ ឆ្នាំ២០១៨ សម្រាប់សំណុំរឿង ០០៤ ទាក់ទងនឹង យឹម ទិត្យ)។

## II. វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស

១០. ដំណើរការប្រកបដោយប្រសិទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ កន្លងទៅត្រូវបានរំខានដោយអសន្តិសុខផ្នែកហិរញ្ញវត្ថុជាច្រើនដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកចំនួនពីររូបបានបោះបង់ការងារក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់មហាសន្និបាតទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំប្រតិទិន ២០១៤ និង ២០១៥ សម្រាប់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកា និងធ្វើឲ្យមានការផ្តោតមូលទៅលើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ ទោះជាយ៉ាងណា ផ្នែកភាគីជាតិ ភាពលំបាកខាងលំហូរសាច់ប្រាក់បាននាំឱ្យមានការពន្យារជាដដែលៗក្នុងការបើកប្រាក់ខែឱ្យបុគ្គលិកជាតិ ក្នុងរយៈពេលពាក់កណ្តាលឆ្នាំ២០១៥ ដែលនាំឱ្យមានផលប៉ះពាល់ដល់ការផ្តោតនិងសីលធម៌របស់បុគ្គលិក។

១១. បន្ទាប់ពីមានការប្តេជ្ញាចិត្តគាំទ្រពីមុនពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ នៅក្នុងសេចក្តីសម្រេចចិត្តរបស់ខ្លួនលេខ ៧០/២៤៨ ក្នុងនាមជាវិធានការពិសេស មហាសន្និបាតបានអនុញ្ញាតឲ្យអគ្គលេខាធិការសន្យាជាផ្លូវការក្នុងការផ្តល់ថវិកាចំនួនមិនលើសពី ១២.១ លានដុល្លារអាមេរិក ដើម្បីបន្ថែមទៅលើធនធានហិរញ្ញវត្ថុស្ម័គ្រចិត្តរបស់ភាគីអន្តរជាតិ នៃ អ.វ.ត.ក. សម្រាប់រយៈពេលចាប់ពីថ្ងៃទី១ ខែមករា

[5] ដូចដែលកត់សម្គាល់ត្រង់កថាខណ្ឌទី៤៦ ខាងក្រោម ដោយសារស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករនូវចំណុចពេលវេលាជាក់លាក់ ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។

ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ វិធានការទាន់ពេលវេលានេះ បានជួយសម្រួលយ៉ាងខ្លាំងដល់ប្រតិបត្តិការដ៏រលូនរបស់ អ.វ.ត.ក. នៅក្នុងអំឡុងត្រីមាសទីមួយ ឆ្នាំ២០១៦ នេះ ដោយបើកចំហរសម្រាប់ការអំពាវនាវជាបន្តរកការផ្តល់វិភាគទានស្ម័គ្រចិត្ត។ ជាងនេះទៀត ការសន្យាផ្តល់វិភាគទានដោយផ្ទាល់របស់រាជរដ្ឋាភិបាល ដូចឆ្នាំ២០១៥ ដែរ ដើម្បីចំណាយលើថ្លៃបុគ្គលិកជាតិក្នុងរយៈពេលប្រាំមួយខែដំបូង ក៏ដូចជាថ្លៃប្រតិបត្តិការដែលមានក្នុងឆ្នាំ២០១៦ គឺជាវិធានការបំពេញបន្ថែមយ៉ាងសំខាន់ ដែលជួយសម្រួលដំណើរការប្រតិបត្តិការជាបន្តរបស់ភាគីជាតិនៃ អ.វ.ត.ក.។ ជារួម វិធានការទាំងអស់នេះ ធានាបានថាដំណាក់កាលបន្តបន្ទាប់នៃបន្ទុកការងារដ៏ច្រើនខ្លាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ បន្តទទួលបានការចាប់អារម្មណ៍ជានិច្ចក្នុងឆ្នាំ២០១៦។ ការប៉ាន់ស្មានលើតារាងកំណត់ពេលវេលាខាងក្រោម ត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានថា អង្គជំនុំជម្រះ និងការិយាល័យទាំងអស់មានបុគ្គលិកគ្រប់គ្រាន់ និងថាកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ នឹងមិនត្រូវរំខានបន្ថែមទៀតដោយសារតែអសន្តិសុខផ្នែកហិរញ្ញវត្ថុ។ ប្រសិនបើអសន្តិសុខផ្នែកហិរញ្ញវត្ថុលេចឡើង យើងអាចចាំបាច់ត្រូវកែសម្រួលតារាងកំណត់ពេលវេលានេះឡើងវិញ។

១២. ការប៉ាន់ស្មាននានាលើគម្រោងបញ្ចប់ផែនការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០២ បណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ និងការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ សន្មតថាសកម្មភាពទាំងអស់ កំពុងត្រូវបានធ្វើឡើងដំណាលៗគ្នា។ សហព្រះរាជអាជ្ញនឹងចូលរួមក្នុងពេលជាមួយគ្នានៅក្នុងការជំនុំជម្រះ និងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២ និងការស៊ើបអង្កេត និងការរៀបចំដីកាសន្និដ្ឋានស្ថាពរក្នុងសំណុំរឿង ០០៣ និង ០០៤។

១៣. នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក. បានអនុម័តវិសោធនកម្មទៅលើវិធានផ្ទៃក្នុងរបស់តុលាការ ដែលអនុញ្ញាតឲ្យមានការកាត់បន្ថយទៅលើវិសាលភាពកិច្ចស៊ើបសួរ ដ៏រាបណាវិសាលភាពស៊ើបអង្កេតដែលបានកាត់បន្ថយ ជាតំណាងឲ្យបទចោទ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យតាមការចោទប្រកាន់។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងអាចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះក្តីដោយដកចេញអង្គហេតុជាក់លាក់មួយចំនួន ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដ៏រាបណាអង្គហេតុដែលនៅសល់ដែលត្រូវជំនុំជម្រះ គឺជាដំណាងនៃវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វិសោធនកម្មទាំងនេះ ប្រសិនបើអនុវត្តបាន គឺអាចពន្លឿនការបញ្ចប់កិច្ចនីតិវិធីស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តវាយតម្លៃទៅលើ ថាតើវិធានថ្មីទាំងនេះអាចយកមកអនុវត្ត ដើម្បីពង្រួញវិសាលភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ដែរ ឬយ៉ាងណា។

១៤. ក្នុងគោលបំណងបង្កើនសមត្ថភាពស៊ើបអង្កេត របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្រសួងយុត្តិធម៌បានផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំបួននាក់ ដើម្បីចុះធ្វើកំណត់ហេតុស្តាប់ចម្លើយ ដែលជាធម្មតាជាកិច្ចការបំពេញដោយអ្នកស៊ើបអង្កេតប៉ុណ្ណោះ។ ការបង្កើនសមត្ថភាពក្នុងការចុះធ្វើកំណត់ហេតុស្តាប់ចម្លើយនេះ នឹងជំរុញល្បឿននៃការស៊ើបអង្កេត។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចាប់អនុវត្តគំនិតផ្តួចផ្តើមនានា ដើម្បីបង្កើនធនធានមនុស្សរបស់ខ្លួនជាមួយនឹងបុគ្គលិកជំនាញក្រោមកម្មវិធីដែលមិនត្រូវសងវិញ និងកម្មសិក្សាការីបន្ថែមទៀត ដើម្បីបង្កើនផលិតភាពនៃកិច្ចស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តទាក់ទងរដ្ឋជាសមាជិក និងអង្គការវិជ្ជាជីវៈនានាក្នុងគោលបំណងជ្រើសរើសអ្នកស៊ើបអង្កេតបន្ថែមមកបំពេញការងារជាបុគ្គលិកមិនយកប្រាក់កម្រៃ។

១៥. ការិយាល័យរដ្ឋបាល បានជ្រើសរើសបុគ្គលិកបកប្រែភាសាក្រៅក្របខណ្ឌមួយចំនួន ដើម្បីគាំទ្រដល់ការិយាល័យតុលាការ និងអង្គជំនុំជម្រះ ដើម្បីធានាបាននូវសេវាបកប្រែភាសាទាន់ពេលវេលា។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

១៦. កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានផ្តួចផ្តើមឡើង បន្ទាប់ពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងខែកញ្ញា ឆ្នាំ២០០៩។ សហព្រះរាជអាជ្ញាអន្តរជាតិ ជាបន្តបន្ទាប់ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាច្រើន។ សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ បានធ្វើកំណត់ហេតុនៃករណីខ្វែងយោបល់មួយចំនួន ទាក់ទងនឹងការស៊ើបអង្កេតក្នុងរឿងក្តីទាំងអស់នេះ ហើយបានប្រើប្រាស់វិធីសាស្រ្តផ្សេងគ្នា។ ទោះបីមានទស្សនៈផ្សេងគ្នាលើបញ្ហាអង្គហេតុ និងអង្គច្បាប់មួយចំនួនយ៉ាងណាក្តី ក៏កិច្ចសហប្រតិបត្តិការរវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ មានភាពល្អប្រសើប្រកបដោយវិជ្ជាជីវៈខ្ពស់។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែស៊ើបអង្កេតយ៉ាងសកម្ម លើការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងសំណុំរឿង ០០៣ និង ០០៤ ហើយចៅក្រមទាំងពីរធ្វើការជាមួយគ្នាក្នុងសំណុំរឿង ០០៤/០១។

១៧. ចាប់តាំងពីការចាប់ផ្តើមការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ មក បេសកកម្មដល់ទីកន្លែងកើតហេតុសរុបចំនួន ២៣៥ លើក ត្រូវបានធ្វើឡើង ហើយបានធ្វើការស្តាប់ចម្លើយសាក្សីចំនួន ១.២៧០ នាក់។ នៅក្នុងរយៈពេលប្រាំមួយខែដំបូងក្នុងឆ្នាំ២០១៦ មានបេសកកម្មដល់ទីកន្លែងកើតហេតុចំនួន ៣៤ លើក និងបានធ្វើការស្តាប់ចម្លើយសាក្សីចំនួន ១៦១ នាក់។

១៨. ការិយាល័យសហចៅក្រមស៊ើបអង្កេត កំពុងស្វែងរកយ៉ាងសកម្មនូវមធ្យោបាយច្នៃប្រឌិត និងជាក់ស្តែងនៅក្នុងក្របខណ្ឌនីតិវិធីនៃច្បាប់ និង វិធានផ្ទៃក្នុង របស់អង្គជំនុំជម្រះវិសាមញ្ញ ដើម្បីស្វែងរកលទ្ធភាពសម្រាប់ការបង្រួម និងការផ្តោតការស៊ើបអង្កេតបន្ថែម ឱ្យបានមុនចំណុចចាប់ផ្តើមតាមនីតិវិធីនៃវិធាន ៦៦*ស្ទួន*[6] ដែលអាចធ្វើបានតែនៅចុងបញ្ចប់ការស៊ើបអង្កេតប៉ុណ្ណោះ ដែលការណ៍នេះវាយូរពេកសម្រាប់ធានាបាននូវការកាត់បន្ថយការស៊ើបអង្កេតដំបូង។

១៩. ទោះបីជាអង្គហេតុដែលថា សហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ចបង្ហាញទស្សនៈគតិយុត្តិរបស់ខ្លួនដោយស្មានជាមុននៃតម្រូវការជាក់ស្តែងក្នុងការសម្រេចលើបញ្ហាច្បាប់យ៉ាងណាក្តី ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តែងតែចេញសេចក្តីជូនដំណឹងមានសំអាងហេតុលម្អិតលើទស្សនៈរបស់គាត់ ទាក់ទងនឹងច្បាប់ជាធរមាន ក្នុងគោលបំណងដោះស្រាយបញ្ហាគតិយុត្តិសំខាន់ៗ និងចម្រូងចម្រាសមួយចំនួន នៅមុនពេលដំណាក់កាលដីកាដំណោះស្រាយ។ ការណ៍នេះរួមបញ្ចូលបញ្ហានានាដូចជា ល័ក្ខខណ្ឌតម្រូវនៃចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងកន្លងមកមានទស្សនៈផ្ទុយគ្នា និងដែលការណែនាំពីអង្គជំនុំជម្រះតុលាការកំពូលនៅតែមិនដាច់ស្រេច និងញត្តិស្តីពីការមានគភ៌ដោយបង្ខំ/ការបង្ខំឱ្យមានគភ៌ ដែលបានរៀបរាប់ក្នុងកថាខណ្ឌ ៣៥ ខាងក្រោម។

២០. តារាងកំណត់ពេលវេលានៃការបញ្ចប់ការស៊ើបអង្កេតកំពុងបន្តនេះ ត្រូវបានកំណត់ដោយកត្តានានាដូចជា៖ ប្រភេទ និងភាពស្មុគស្មាញនៃរឿងក្តី ចំនួនសាក្សីដែលត្រូវស្តាប់ចម្លើយ ចំនួនបេសកកម្មចុះដល់ទីកន្លែងដែលតម្រូវឲ្យមាន លទ្ធភាពមានបុគ្គលិកមានគុណវុឌ្ឍិ និងសម័ត្ថភាពក្នុងការរក្សាទុកបុគ្គលិកដែលមានបទពិសោធន៍ ឧបសគ្គជាក់ស្តែងនិងឧបសគ្គធនធានសម្ភារៈក្នុងការបំពេញកិច្ចស៊ើបសួរ។ ក្នុងបរិបទនេះ វាមានសារៈសំខាន់ក្នុងការបង្ហាញថា ការស៊ើបអង្កេតមិនអាចអនុវត្តទៅបានយ៉ាងស៊ីចង្វាក់គ្នា និងទៀងទាត់គ្រប់ពេលបានឡើយ នៅទូទាំងឆ្នាំ ក៏ដូចជាក្នុងបរិយាកាសផ្សេងទៀតផងដែរ។ មានថ្ងៃឈប់សម្រាកបុណ្យជាតិជាច្រើនដែលនៅពេលនោះបុគ្គលិកជាតិមិនមានពេលចូលរួមក្នុងការស្តាប់ចម្លើយសាក្សី ហើយសាក្សីអាចមិនទំនេរផងដែរ។ ជាងនេះទៀត ក្នុងអំឡុងពេលបង្កបង្កើនផលស្រូវ និងនៅរដូវប្រមូលផលស្រូវ សាក្សីសក្តានុពលមិនងាយ

---

[6] វិធាន ៦៦*ស្ទួន* អនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតដកអង្គហេតុជាក់លាក់មួយចំនួនចេញពីការស៊ើបអង្កេត ដរាបនាអង្គហេតុដែលនៅសល់គឺជាតំណាងគ្រប់គ្រាន់នៃវិសាលភាពរបស់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ វិធាននេះមិនទាន់ត្រូវបានយកមកប្រើជាលើកដំបូងនៅឡើយទេ។

មានពេលទំនេរដើម្បីផ្តល់បទសម្ភាសន៍នោះទេ។ ទីតាំងដាច់ស្រយាលមួយចំនួន ជាក់ស្តែងបេសកកម្មមិនអាចធ្វើដំណើរចូលទៅដល់បានទេ ក្នុងផ្នែកខ្លះនៅរដូវភ្លៀង បើសិនជាមិនមានផ្លូវល្អនោះ។ សាក្សីខ្លះរស់នៅបរទេស ដែលការណ៍នេះបន្ថែមភាពស្មុគស្មាញបន្ថែមទៀត ទៅលើដំណើរការស៊ើបអង្កេត។ គម្រោងពេលវេលារបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតផ្អែកលើកត្តាមួយចំនួន *ជាអាទិ៍* ដូចជា មិនមានការចាកចេញនៃបុគ្គលិកសំខាន់ៗ ថវិកាគ្រប់គ្រាន់សម្រាប់ការជ្រើសរើសបុគ្គលិកថ្មី និងមានគុណវុឌ្ឍិ ដើម្បីបំពេញមុខតំណែងដែលនៅទំនេរ ការបកប្រែឯកសារទាន់ពេលវេលា សមត្ថភាពក្នុងការបកប្រែផ្ទាល់មាត់គ្រប់គ្រាន់ និងសមត្ថភាពក្នុងការធ្វើប្រតិចារឹកដើម្បីគាំទ្របេសកកម្មដល់ទីកន្លែងកើតហេតុ និងការស្តាប់ចម្លើយសាក្សី ដំណោះស្រាយទាន់ពេលវេលាចំពោះបណ្តឹងឧទ្ធរណ៍មួយ ដែលដាក់ទៅអង្គបុរេជំនុំជម្រះ និងការគាំទ្រពេញលេញពីនគរបាលយុត្តិធម៌សម្រាប់កិច្ចស៊ើបសួរណាមួយដែលត្រូវការធាតុផ្សំអនុវត្តន៍។

២១. ចំនួនញត្តិដាក់ដោយភាគី ក៏ដូចជា ពេលវេលាដែលត្រូវការដោយអង្គបុរេជំនុំជម្រះ ក្នុងការចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ហំ ក៏មានផលប៉ះពាល់លើតារាងកំណត់ពេលវេលានេះដែរ។ ការដាក់ញត្តិនិងមានកាន់តែច្រើនក្នុងរឿងក្តីនីមួយៗ ខណៈដែលការបិទការស៊ើបអង្កេតខិតជិតមកដល់ ជាពិសេសដោយសារតែអានុភាពនៃដីកាដំណោះស្រាយ ដែលកែតម្រូវវិការៈនីតិវិធីទាំងអស់ នៅក្នុងការស៊ើបអង្កេតតាមវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង។ អាស្រ័យលើទំហំ និងភាពស្មុគស្មាញនៃញត្តិ វាអាចចំណាយពេលពីពីរ ទៅបីខែ ចាប់ពីពេលដាក់ញត្តិ ដើម្បីធ្វើសេចក្តីព្រាងសេចក្តីសម្រេចដំបូង។ ពេលវេលាណាមួយដែលត្រូវការសម្រាប់បណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ត្រូវតែគិតបញ្ចូល បច្ចុប្បន្នគិតជាមធ្យមមានរយៈពេលប្រាំមួយខែ។ ដោយផ្អែកលើកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ គឺផ្អែកលើបទពិសោធន៍កន្លងទៅនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងត្រូវគិតទុកជាមុនថាជាការប៉ាន់ស្មានជារួម។ វាក៏មានសារៈសំខាន់ផងដែរក្នុងការស្វែងយល់ថា កត្តាដែលបានរៀបរាប់មួយចំនួនខាងលើ គឺស្ថិតនៅហួសពីការគ្រប់គ្រងរបស់សហចៅក្រមស៊ើបអង្កេត ក៏ដូចជាគម្រោងដែលបានគ្រោងទុកដែរ។ ដូច្នេះ ការកែសម្រួលតារាងកំណត់ពេលវេលាគប្បីត្រូវបានព្យាករទុកជាមុន។

២២. ការផ្គត់ផ្គង់បុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវបានបំពេញបន្ថែមដោយមានជំនួយពីបុគ្គលិកមិនយកប្រាក់កម្រៃមកពីរដ្ឋសមាជិក ជាពិសេស កាណាដា និងកម្មសិក្សាការីមួយចំនួនធំ។ កម្រិតបុគ្គលិកបច្ចុប្បន្នធ្វើឱ្យការិយាល័យចុះខ្សោយ ក្នុងករណីដែលមានការផ្លាស់ប្តូរបុគ្គលិក ហើយវាក៏ប៉ះពាល់ដល់សមត្ថភាពរបស់ខ្លួនក្នុងការទទួលយកការងារបន្ថែម ដែលកើតឡើងមកពីការដាក់ឯកសារតុលាការដោយភាគី និង/ឬ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយអង្គបុរេជំនុំជម្រះ។ បុគ្គលិកមានបទពិសោធន៍មួយចំនួនបានលាឈប់ក្នុងរយៈពេលនៃត្រីមាសទីមួយ ឆ្នាំ២០១៦ ហើយវាត្រូវការចំណាយពេលច្រើនក្នុងជ្រើសរើស និងបណ្តុះបណ្តាលបុគ្គលិកជំនួស និង/ឬ ធ្វើការរៀបចំបន្ទុកការងារឡើងវិញ។ ការផ្លាស់ប្តូរបុគ្គលិកនេះមានផលប៉ះពាល់អវិជ្ជមានលើការងារដែលកំពុងធ្វើ។

២៣. វិធានផ្ទៃក្នុងដាក់បញ្ញត្តិអំពីដំណាក់កាលនីតិវិធីផ្សេងៗ ដែលសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តតាម ដើម្បីបំពេញឲ្យបានពេញលេញនូវដំណើរការស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវស៊ើបអង្កេតអង្គហេតុនានាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលដាក់ដោយសហព្រះរាជអាជ្ញា។ ភាគីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរជាក់លាក់ ហើយការណ៍នេះអាចនាំឱ្យមានកិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេតសំខាន់ៗ អាស្រ័យលើកាលៈទេសៈជាក់ស្តែង។ ការបដិសេធមិនពិចារណាលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ អាចនឹងត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ហើយផ្អែកលើបទពិសោធពីមុនបង្ហាញថា អង្គបុរេជំនុំជម្រះអាចត្រូវការពេលវេលារហូតដល់ប្រាំមួយខែ ឬច្រើនជាងនេះ ដើម្បីធ្វើសេចក្តីសម្រេចលើញត្តិបែបនោះ។ អាស្រ័យលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ និងលទ្ធផលរបស់វា សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍អាចមានផលប៉ះពាល់សំខាន់លើការស៊ើបអង្កេតដែលកំពុងធ្វើ និងបន្ថែមបន្ទុកយ៉ាងច្រើនទៅលើពេលវេលាដែលត្រូវការបញ្ចប់ពួកវា។ ការណ៍នេះក៏ដូចគ្នា

ទៅនឹងសំណើសុំមោឃភាព ដែលដាក់ទៅកាន់អង្គបុរេជំនុំជម្រះផងដែរ ទាក់ទងនឹងការចោទប្រកាន់អំពីការបំពេញកិច្ចស៊ើបសួរខុសច្បាប់ ដោយសារតែសហចៅក្រមស៊ើបអង្កេតមិនមានអំណាចធ្វើមោឃភាពកិច្ចស៊ើបសួររបស់ខ្លួនផ្ទាល់ សូម្បីតែសហចៅក្រមស៊ើបអង្កេតយល់ឃើញថាការស៊ើបអង្កេតទាំងនោះមានវិការៈ។

២៤. នៅពេលសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ការស៊ើបអង្កេតត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ភាគីទាំងអស់ ដែលមានរយៈពេល១៥ថ្ងៃដើម្បីស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម លើកលែងតែភាគីបោះបង់រយៈពេលនោះចោល។ រាល់ការយោងទាំងអស់ទៅកាន់ការបិទបញ្ចប់ការស៊ើបអង្កេត នៅក្នុងគម្រោងបញ្ចប់ផែនការនេះ សំដៅលើការផុតកំណត់រយៈពេល ១៥ ថ្ងៃ ដែលបានផ្តល់ឱ្យក្នុងវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង បន្ទាប់ពីការជូនដំណឹងអំពីការបិទ។ មិនមានវិធីគួរឱ្យទុកចិត្តណាក្នុងការព្យាករណ៍ឱ្យបានត្រឹមត្រូវនូវពេលវេលាដែលខ្លួនអាចប្រើ ដើម្បីឆ្លើយតបទៅនឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរណាមួយ ដែលបានដាក់ក្នុងអំឡុងរយៈពេលនោះឡើយ។

២៥. ប្រសិនបើសហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធចោលសំណើបែបនេះ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចមួយ ដែលមានសំអាងហេតុ។ នៅក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ ភាគីទាំងអស់អាចដាក់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ អាស្រ័យលើចំនួនបណ្តឹងឧទ្ធរណ៍ និងពេលវេលាដែលត្រូវការសម្រាប់អង្គបុរេជំនុំជម្រះធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍បែបនោះ ផ្នែកនៃដំណើរការនេះអាចចាំបាច់ឱ្យមានការកែប្រែបន្ថែមទៀតទៅលើតារាងកំណត់ពេលវេលានេះ។ គេមិនអាចព្យាករពេលវេលាច្បាស់លាស់ដែលត្រូវការសម្រាប់បណ្តឹងឧទ្ធរណ៍ណាមួយ ដែលបានដាក់ប្រឆាំងនឹងសំណើបែបនោះឡើយ ប៉ុន្តែផ្អែកលើបទពិសោធន៍ពីមុន វាអាចចំណាយពេលរហូតដល់ប្រាំមួយខែ ឬច្រើនជាងនេះនៅក្នុងករណីនីមួយៗ។

២៦. លុះត្រាតែនៅពេលដែលរយៈពេល ៣០ ថ្ងៃ ត្រូវបានផុត ត្រូវបានបោះបង់ចោល ឬបណ្តឹងឧទ្ធរណ៍ខាងលើត្រូវបានបើកសវនាការជំនុំជម្រះ ទើបសហចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញាដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ ក្នុងរយៈពេល ៤៥ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវបានឃុំខ្លួន និងរយៈពេល ៣ ខែ នៅក្នុងករណីផ្សេងៗទៀត។ ពុំមានជនត្រូវចោទណាម្នាក់ស្ថិតក្រោមការឃុំខ្លួននោះទេបច្ចុប្បន្ននេះ។ បន្ទាប់មកមេធាវីការពារក្តីត្រូវតែមានពេលវេលាគ្រប់គ្រាន់ដើម្បីឆ្លើយតប។ លើកលែងតែក្រោយពេលដំណាក់កាលដែលលើកឡើងខាងលើនេះត្រូវបានបញ្ចប់ ទើបសហចៅក្រមស៊ើបអង្កេតអាចចេញដីកាដំណោះស្រាយថាតើត្រូវចោទប្រកាន់ជនត្រូវចោទ ដែលត្រូវបញ្ជូនរូបគាត់ទៅជំនុំជម្រះ ឬត្រូវទម្លាក់ចោលការចោទប្រកាន់។

២៧. សហព្រះរាជអាជ្ញាអាចនឹងដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បណ្តឹងឧទ្ធរណ៍ តែក្នុងករណីដីកាដំណោះស្រាយបដិសេធចោលការចោទប្រកាន់ និងក្នុងករណីដែលសហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធចោលការចោទប្រកាន់នេះ។ បន្ថែមពីលើនេះ អង្គបុរេជំនុំជម្រះបានផ្តល់សិទ្ធិឲ្យជនត្រូវចោទជំទាស់នឹងធាតុផ្សំយុត្តាធិការនៅក្នុងដីកាដំណោះស្រាយតាមរយៈបណ្តឹងឧទ្ធរណ៍។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវតែដាក់នៅក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ។ អង្គបុរេជំនុំជម្រះអាចនឹងកែប្រែ ឬតម្កល់ដីកាដំណោះស្រាយនេះ។

២៨. ការគណនាតារាងកំណត់ពេលវេលានេះចាំបាច់ត្រូវមានការកែប្រែជាច្រើន ដោយសារកត្តាពីរយ៉ាង ទីមួយការព្យាករណ៍ត្រូវបានកែប្រែទាក់ទងនឹងដំណាក់កាលនីតិវិធីមួយចំនួន ហើយទីពីរ បញ្ហាភស្តុភារដូចជា ពេលវេលាធ្វើសេចក្តីព្រាង (រួមបញ្ចូលទាំង ការបកប្រែភាសា) ដែលទាក់ទងនឹងបញ្ហានេះ ពេលវេលាដែលត្រូវការទើបតែមានភាពច្បាស់លាស់នាពេលថ្មីៗនេះប៉ុណ្ណោះ ដោយសារមូលហេតុនានារួមមានសកម្មភាពនីតិវិធីកាន់តែច្រើនឡើងរបស់ភាគី។ គឺបញ្ហាទីពីរនេះហើយដែលជំរុញជាសំខាន់ទៅលើការបន្ថែមពេលវេលាដែលបានកំណត់នៅក្នុងរបាយការណ៍នេះ។

២៩. ការបកប្រែភាសាបានទាន់ពេលវេលា នឹងមានផលប៉ះពាល់ពិសេសក្នុងអំឡុងពេលដំណាក់កាលធ្វើសេចក្តីព្រាងដីកាដំណោះស្រាយ មិនត្រឹមតែអត្ថបទនៃដីកាដំណោះស្រាយប៉ុណ្ណោះទេ ដែលត្រូវការបកប្រែថែមទាំងអត្ថបទជាភាសាខ្មែរក៏តម្រូវឱ្យមានការធ្វើការត្រួតពិនិត្យឯកសារយោងនៅក្នុងកំណត់សម្គាល់ជើងទំព័រដាច់ដោយឡែក ដោយសារតែទម្រង់ជាភាសាខ្មែរ នឹងសម្ភារៈផ្សេងទៀតមិនដូចគ្នាទាំងស្រុង ឧទាហរណ៍ទាក់ទងនឹងចំនួនទំព័រ ។ល។

៣០. ការិយាល័យសហចៅក្រមស៊ើបអង្កេត មានបំណងកាត់បន្ថយការធ្វើសេចក្តីព្រាងដីកាដំណោះស្រាយ ឱ្យបានច្រើនដូចដែលអាចធ្វើទៅបាន នៅពេលណាដែលខ្លួនអាចធ្វើបាន និងត្រឹមត្រូវតាមខ្លឹមសាររបស់សេចក្តីសម្រេច។ តារាងកំណត់ពេលវេលាសម្រាប់ការធ្វើសេចក្តីព្រាងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០១ និង ០០២ មានចាប់ពីប្រមាណបីខែក្នុងសំណុំរឿង ០០១ ដែលពាក់ព័ន្ធនឹងសេណារីយ៉ូមានកម្រិតតិចជាង ទៅដល់ប្រាំបីខែក្នុងសំណុំរឿង ០០២ ដែលជាប្រភេទមួយដែលឆ្លុះបញ្ចាំងភាពស្មុគស្មាញប្រហាក់ប្រហែលគ្នាទៅនឹងរឿងក្តី យឹម ទិត្យ បច្ចុប្បន្ន។

៣១. ជាងនេះទៀត គួរចងចាំផងដែរថា ការិយាល័យ ដែលមានបុគ្គលិកតិចនិងមិនទាងទាត់ ត្រូវធ្វើការលើមុខព្រួញបួន មុខព្រួញមួយក្នុងចំណោមនោះគឺ សំណុំរឿង ០០៤/០១ ដែលមិនសូវមានសកម្មភាព តែនៅតែជាបន្ទុកការងារសំខាន់ រហូតដល់ពេលចេញដីកាដំណោះស្រាយ។

៣២. កត្តារួមផ្សំបញ្ចូលគ្នានេះបង្កើតបានជាផលប៉ះពាល់បន្ទាប់បន្សំ នៅក្នុងរឿងក្តីនីមួយៗ ដែលនាំឱ្យមានរយៈពេលជាមធ្យមប្រាំមួយខែ ចន្លោះពេលបិទកិច្ចស៊ើបសួរ និងពេលចេញដីកាដំណោះស្រាយ ដូចពន្យល់ខាងក្រោម។

៣៣. បន្ទាប់ពីការចោទប្រកាន់បន្ថែម ក្នុងខែធ្នូ ឆ្នាំ២០១៥ កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ប្រឆាំងនឹង មាស មុត បានបន្តរីកច្រើនទៅមុខ ទោះជាយ៉ាងណា វាមិនដូចការរំពឹងទុកនោះទេ ដោយសារកត្តាមួយចំនួនដូចជា តម្រុយថ្មីដែលមិនទាន់បានស្រាវជ្រាវ និងត្រូវធ្វើការស្តាប់ចម្លើយសាក្សីសំខាន់ៗ។ ក៏មានញត្តិច្រើនផងដែរនៅក្នុងរឿងក្តីនេះ។ ការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរអាចធ្វើទៅបាននៅចុងត្រីមាសទីបួន ឆ្នាំ២០១៦។ ដូច្នេះ ដីកាដំណោះស្រាយនឹងមិនអាចចេញបានទេ រហូតដល់ចុងត្រីមាសទីពីរ ឆ្នាំ២០១៧ និងអាចក្រោយនេះទៀត ប្រសិនបើមានសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរច្រើននោះ។

៣៤. ក្នុងសំណុំរឿង០០៤ យឹម ទិត្យ ពេលនេះបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពេញលេញ បន្ទាប់ពីមេធាវីការពារក្តីរបស់គាត់ត្រូវបានអនុញ្ញាតឱ្យចូលពិនិត្យសំណុំរឿង នៅខែធ្នូ ឆ្នាំ២០១៥។ ក្រុមមេធាវីការពារក្តីកំពុងតែមានការរីកចម្រើនយ៉ាងខ្លាំងក្នុងការពិនិត្យសំណុំរឿង និងបានកែសម្រួលការផ្គត់ផ្គង់បុគ្គលិករបស់ខ្លួនរួចរាល់ហើយ។ ដូច្នេះ រំពឹងថានឹងមានសកម្មភាពដាក់ញត្តិកាន់តែច្រើនឡើង ជាពិសេសក្នុងទម្រង់ជាញត្តិស្នើសុំមោឃភាព និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ និងទំនងជាចាប់ផ្តើមច្រើនបំផុតនៅត្រីមាសទីបួន ឆ្នាំ២០១៦។ សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសំណើដាច់ដោយឡែកមួយដោយសហព្រះរាជអាជ្ញាអន្តរជាតិស្តីពីការមានគភ៌ដោយបង្ខំ និងការបង្ខំឱ្យមានគភ៌ ត្រូវបានបដិសេធដោយសេចក្តីសម្រេចចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ផ្នែកខ្លះដោយសារតែបញ្ហាចោទពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាព (nullum crimen) ប៉ុន្តែផ្នែកខ្លះទៀតក៏ដោយសារតែសំណើទាំងពីរនេះបានដាក់យឺតពេក និងមិនមានមូលហេតុច្បាស់លាស់ត្រូវបានបង្ហាញដោយភាគីណាមួយ ស្តីពីមូលហេតុដែលបញ្ហានេះមិនត្រូវបានលើកឡើងច្រើនឆ្នាំមកហើយ នៅពេលដែលបញ្ហានេះបានលេចឡើងរួចហើយនោះ ដូច្នេះបានបណ្តាលឱ្យប៉ះពាល់ដល់ប្រយោជន៍របស់ភាគីការពារក្តី នាំឱ្យមានការពន្យារពេលការស៊ើបអង្កេត និងប៉ះពាល់ដល់ការបែងចែកធនធានដ៏មានកម្រិតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ប្រសិនបើសេចក្តីសម្រេចនេះត្រូវបានប្តឹងឧទ្ធរណ៍នោះ និងក្រោយមកត្រូវបានបដិសេធចោលដោយអង្គបុរេជំនុំជម្រះវិញនោះ វាច្បាស់ណាស់ថាតារាងកំណត់ពេលវេលានៅក្នុងរឿងក្តីនេះនឹងត្រូវកែប្រែឡើងវិញបន្ថែមទៀត។ រួមជាមួយនឹងក្តីកង្វល់ផ្នែក

ភ័ស្តុភារដែលបានលើកឡើងខាងលើ កាលបរិច្ឆេទសម្រាប់ការចេញសេចក្តីជូនដំណឹងបិទកិច្ចស៊ើបសួរ ត្រូវបានកែប្រែមកត្រីមាសទីមួយ ឆ្នាំ២០១៧ ដោយដីកាដំណោះស្រាយគ្រោងនឹងចេញនៅត្រឹមចុងត្រីមាសទីបី ឆ្នាំ២០១៧ ដែលអាចនឹងយូរជាងនេះ បើសិនជាមានការដាក់ញត្តិច្រើនបន្ទាប់ពីការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ។

៣៥. នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឱ្យបំបែករឿងក្តី អ៊ឹម ចែម ពីសំណុំរឿង ០០៤។ ដូច្នេះ សំណុំរឿងថ្មីមានឈ្មោះថា សំណុំរឿង ០០៤/០១ ត្រូវបានបង្កើតឡើង ហើយបច្ចុប្បន្ននេះកំពុងដំណើរការដាច់ដោយឡែកពីសំណុំរឿង ០០៤។ ដំណាក់កាលនីតិវិធីបន្ទាប់ឆ្ពោះទៅដីកាដំណោះស្រាយគឺការបញ្ជូនសំណុំរឿង ០០៤/០១ ទៅការិយាល័យសហព្រះរាជអាជ្ញា ដើម្បីធ្វើដីកាសន្និដ្ឋានស្ថាពរ ហើយបន្ទាប់មកសម្រាប់មេធាវីការពារក្តីឆ្លើយតប។ យ៉ាងណាមិញ ផ្ទុយទៅនឹងរបាយការណ៍បញ្ចប់ផែនការចុងក្រោយ នៅពេលដែលមានការពន្យារពេលរហូតដល់បីខែត្រូវបានលើកឡើង ដោយសារតែញត្តិសុំមោឃភាពនោះ បច្ចុប្បន្ននេះអាចមានការពន្យារពេលបន្ថែមទៀតចំនួនបីខែ ឬច្រើនជាងនេះ ដោយសារសហមេធាវីការពារក្តី អ៊ឹម ចែម បានទទួលមរណភាពដោយចៃដន្យ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦។ សហមេធាវីការពក្តីថ្មីបានស្បថចូលកាន់ដំណែងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦។ ផលប៉ះពាល់នៃការផ្លាស់ប្តូរភ្លាមៗនៅក្នុងក្រុមមេធាវីការពារក្តីលើការវិវឌ្ឍនៃសំណុំរឿង នៅតែមាន។ ស្ថានភាពមិនទៀតទាត់នៅក្នុងសំណុំរឿង ០០៤/០១ មិនអាចឱ្យមានការព្យាករណ៍ច្បាស់លាស់អំពីពេលវេលាសម្រាប់ដីកាដំណោះស្រាយឡើយ ប៉ុន្តែពេលនេះវាអាចរហូតដល់ត្រីមាសទីមួយ ឆ្នាំ២០១៧។ ហេតុដូច្នេះ តារាងកំណត់ពេលវេលាសម្រាប់សំណុំរឿង ០០៤/០១ ត្រូវបានកែប្រែឡើងវិញទៅត្រីមាសទីមួយ ឆ្នាំ២០១៧ វិញ។

៣៦. វានៅតែជាវិធីសាស្ត្រល្អសម្រាប់សហចៅក្រមស៊ើបអង្កេតនៃសំណុំរឿង ០០៤ ក្នុងការបំបែកកិច្ចដំណើរការនីតិវិធីបន្ទាប់ ប្រឆាំងនឹង អោ អាន ខណៈដែលការស៊ើបអង្កេតឈានជិតដល់ទីបញ្ចប់។ យ៉ាងណាក៏ដោយ ជាមួយនឹងបទចោទថ្មីដែលបានប្រកាសកាលពីខែមីនា ឆ្នាំ២០១៦ មេធាវីការពារក្តីស្ថិតក្រោមបន្ទុកធនធានបុគ្គលិកបន្ថែមទៀត។ សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរជាក់លាក់ និងយ៉ាងរសើបមួយ ក៏បានប៉ះពាល់ផងដែរលើការព្យាករណ៍ពេលវេលានៅក្នុងរឿងក្តីនេះដែរ។ សំណើនេះនៅកំពុងរង់ចាំដំណោះស្រាយនៅឡើយ ហើយអាចនាំឱ្យមានភ័ស្តុតាងថ្មីបន្ថែមទៀតជាច្រើន ដែលរកឃើញថាអាចនាំឱ្យមានកិច្ចស៊ើបសួរបន្ថែមទៀត។ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ មេធាវីការពារក្តីបានបញ្ជាក់ទៅកាន់សហចៅក្រមស៊ើបអង្កេត[7]ថា ខ្លួននឹងដាក់ញត្តិពាក់ព័ន្ធនឹងភ័ស្តុតាងយ៉ាងហោចណាស់ចំនួនបីបន្ថែមទៀត (ញត្តិធំពីរ និងតូចមួយ) ក្នុងចំណោមនោះ ញត្តិមួយគឺជាញត្តិសុំមោឃភាពដ៏ធំមួយ ញត្តិធំមួយផ្សេងទៀតគឺជាសំណើសុំឱ្យធ្វើការស៊ើបអង្កេតដ៏ទូលំទូលាយ។ ផ្អែកលើបទពិសោធន៍ជាមួយនឹងញត្តិស្រដៀងគ្នានេះកន្លងមក ការណ៍នេះនឹងបន្ថែមពេលវេលាយ៉ាងច្រើនទៅលើដំណើរការ តាមរយៈចំនួនពេលវេលាដែលត្រូវការដើម្បីពិនិត្យញត្តិ នៅក្នុងការិយាល័យសហចៅក្រមស៊ើងអង្កេតអន្តរជាតិ។ ប្រសិនបើមានញត្តិតែមួយក្នុងចំណោមញត្តិទាំងនោះទៅដល់អង្គបុរេជំនុំជម្រះ ទោះដោយផ្ទាល់ ឬតាមរយៈបណ្តឹងឧទ្ធរណ៍ ការណ៍នេះចាំបាច់នាំឱ្យមានការពន្យារពេលបន្ថែមទៀតលើតារាងកំណត់ពេលវេលាដែលបានគ្រោងទុក រហូតដល់ប្រាំមួយខែ អាចនឹងច្រើនជាងនេះប្រសិនបើញត្តិទាំងពីរត្រូវបានបញ្ជូនទៅអង្គបុរេជំនុំជម្រះ។ តារាងកំណត់ពេលវេលា ពេលនេះត្រូវបានកែប្រែ ដោយមានការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ដែលបានគ្រោងទុកនៅចុងឆ្នាំ២០១៦ ហើយដីកាដំណោះស្រាយនឹងត្រូវចេញនៅចុងត្រីមាសទីពីរ ឆ្នាំ២០១៧ និងយូរជាងនេះប្រសិនបើមានសកម្មភាពដាក់ញត្តិច្រើន បន្ទាប់ពីការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ។ ការព្យាករណ៍ដែលបានកែប្រែដ៏ល្អបំផុតជារួម ដែលអាចផ្តល់ជូននាពេលនេះគឺដូចខាងក្រោម៖

- ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ទាក់ទងនឹង មាស មុត នឹងត្រូវបិទបញ្ចប់ត្រឹមត្រីមាសទីបួន ក្នុងឆ្នាំ២០១៦។

[7] មេធាវីការពារក្តីបានឯកភាពថា ព័ត៌មាននេះអាចត្រូវធ្វើឱ្យទៅជាសាធារណៈក្នុងបរិបទនេះ។

- ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ នឹងចេញត្រឹមចុងត្រីមាសទីពីរ ឆ្នាំ២០១៧។
- ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម នឹងចេញនៅក្នុងត្រីមាសទីមួយ ឆ្នាំ២០១៧
- ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ នឹងបញ្ចប់នៅចុងត្រីមាសទីបួន ឆ្នាំ២០១៦ ពាក់ព័ន្ធនឹង អោ អាន ហើយការណ៍នេះនឹងអមដោយដីកាបំបែកសំណុំរឿង។
- ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ពាក់ព័ន្ធនឹង អោ អាន នឹងត្រូវចេញនៅចុងត្រីមាសទីពីរ ឆ្នាំ២០១៧។
- ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ពាក់ព័ន្ធនឹង យឹម ទិត្យ នឹងបញ្ចប់នៅត្រីមាសទីមួយ ឆ្នាំ២០១៧។
- ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ពាក់ព័ន្ធនឹង យឹម ទិត្យ នឹងត្រូវចេញនៅចុងត្រីមាសទីបី ឆ្នាំ២០១៧។

## IV. ផែនការបញ្ចប់សវនាការ

៣៧. តារាងកំណត់ពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា លក្ខណៈ និងភាពស្មុគស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ លទ្ធភាពចូលរួមបានរបស់ពួកគេ និងរយៈពេលនៃការធ្វើសក្ខីកម្មរបស់សាក្សីទាំងនោះ ការបង្អាក់ជាក់ស្ដែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត រួមមានការបកប្រែភាសាបានត្រឹមត្រូវ និងការបកប្រែឯកសារបានទាន់ពេលវេលា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ គឺផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នា។

៣៨. ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្ដើមសវនាការជាក់ស្ដែង។ សវនាការចាប់ផ្ដើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះសាលាដំបូង ពិចារណាទៅលើបញ្ជីសាក្សីសក្ខានុពល និងអ្នកជំនាញ ដែលដាក់ជូនដោយភាគី ព្រមទាំងអញ្ញត្រកម្មលើកឡើងដោយភាគី ហើយភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចផ្ដួចផ្ដើមនូវចំណុចជាក់លាក់អំពីសំណងដែលខ្លួនស្នើសុំ។ សវនាការលើអង្គសេចក្ដី ចាប់ផ្ដើមដោយមានការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ដោយសង្ខេបពីសំណាក់សហព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន មុនពេលអង្គជំនុំជម្រះសាលាដំបូង ចាប់ផ្ដើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី និងស្ដាប់នូវការបង្ហាញភ័ស្តុតាង។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្ដន្ទាទោសជនជាប់ចោទអង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ក្រោយពេលពិនិត្យភ័ស្តុតាងទាំងអស់រួចហើយ អង្គជំនុំជម្រះស្ដាប់ការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ភាគី មុនពេលពិភាក្សាគ្នាជាសម្ងាត់ដើម្បីសម្រេចសេចក្ដី។ ប្រសិនបើជនជាប់ចោទត្រូវផ្ដន្ទាទោស អង្គជំនុំជម្រះសម្រេចទៅលើទោសសមស្របដែលបានកំណត់នៅក្នុងសាលក្រមរបស់ខ្លួន។ ដោយឈរលើមូលដ្ឋាននៃជំហាននីតិវិធីទាំងនេះ ទើបយើងកំណត់បាននូវគ្រោងការសំខាន់ៗផ្សេងៗគ្នាសម្រាប់សវនាការនីមួយៗបាន។

### ក. សំណុំរឿង០០២/០២

៣៩. កិច្ចដំណើរការនីតិវិធីលើភ័ស្តុតាងបានចាប់ផ្ដើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ដោយអង្គជំនុំជម្រះត្រូវធ្វើសវនាការចំនួនបីថ្ងៃក្នុងមួយសប្ដាហ៍។ លទ្ធផលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទនៅខែមករា ឆ្នាំ២០១៥ បង្ហាញថា ការកំណត់៤ថ្ងៃ ក្នុង១សប្ដាហ៍ជាការសមស្រប ដោយសវនាការពេលព្រឹកធ្វើឲ្យបានខ្លីបន្តិច។ ដូច្នេះអង្គជំនុំជម្រះបានត្រឡប់ទៅអនុវត្តតាមពេលកំណត់៤ថ្ងៃក្នុង១សប្ដាហ៍វិញ នៅខែ

កុម្ភៈ ដែលជាការពន្លឿនដល់ការជំនុំជម្រះក្តី។ ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មសាក្សីចំនួន ៨៦ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤១ នាក់ និង អ្នកជំនាញចំនួន ៣ នាក់ ស្តីពីសហករណ៍ត្រាំកក់ (រួមបញ្ចូល មន្ទីរសន្តិសុខក្រាំងតាចាន់ និងការប្រព្រឹត្តិលើពុទ្ធសាសនិក) ការដ្ឋានទំនប់ ១ មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម ក៏ដូចជាការប្រព្រឹត្តិលើជនជាតិចាម និងជនជាតិវៀតណាម មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល មន្ទីរសន្តិសុខ ស-២១ ក៏ដូចជា ការបោសសម្អាតផ្ទៃក្នុង។ អង្គជំនុំជម្រះរំពឹងថានឹងចាប់ផ្តើមសវនាការលើភ័ស្តុតាង ទាក់ទងនឹងបទបញ្ហាស្តីពីការរៀបអាពាហ៍ពិពាហ៍ ក្នុងអំឡុងត្រីមាសទីបី ឆ្នាំ២០១៦។ ការណ៍នេះនឹងបន្តដោយសវនាការទាក់ទងនឹងវគ្គសវនាការសំខាន់ចំនួនពីរគឺ៖ លក្ខណៈនៃជម្លោះប្រដាប់អាវុធ និងតួនាទីរបស់ជនជាប់ចោទ។

៤០. ចំនួនថ្ងៃសម្រាប់បើកនិងបញ្ចប់សវនាការពេញលេញ គឺអាចស្មានទុកបានទាំងស្រុងក្នុងសំណុំរឿង ០០២/០២ តែនៅពេលណាដែលចំនួនទូទៅនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវកោះហៅ មានការកំណត់ច្បាស់លាស់ហើយដោយអង្គជំនុំជម្រះសាលាដំបូង។ សក្ខីកម្មសរុបចំនួន ២៦៥ ត្រូវបានស្នើឡើងដោយភាគី។ សក្ខីកម្មចំនួន ៨១ បន្ថែមទៀតរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មី ត្រូវបានស្នើឡើងតាំងពីចាប់ផ្តើមសវនាការ។ ដូច្នេះ ការស្មានទុកពេលបច្ចុប្បន្នទាក់ទិននឹងតារាងពេលវេលានៃសំណុំរឿង០០២/០២ គឺផ្អែកទៅលើការសន្មតថា សវនាការទីពីរនឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាដូចគ្នានឹងសវនាការ០០២/០១ ដែរ ប៉ុន្តែអាចខុសប្លែកពីគ្នាច្រើន នៅពេលដែលកត្តានេះត្រូវបានកំណត់ពេញលេញ។

៤១. ក្នុងអំឡុងពេលត្រីមាសទីពីរ ឆ្នាំ២០១៦ សវនាការត្រូវបានផ្អាករយៈពេលពីរសប្តាហ៍ ដើម្បីអនុញ្ញាតឱ្យភាគីពិនិត្យឯកសារ ដែលជាមូលដ្ឋាននៃបញ្ជីអ្នកទោស ស-២១ ដែលត្រូវបានដាក់បង្ហាញថ្មីៗ ដែលរៀបចំឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។ បញ្ជីឈ្មោះអ្នកទោសនេះក្រោយមកត្រូវបានទទួលយកក្នុងសំណុំរឿង ០០២/០២ រួមជាមួយនឹងឯកសារបន្ថែមចំនួនប្រមាណ ៨៧០ ដែលជាមូលដ្ឋាននៃបញ្ជីនេះ។ ខណៈដែលអង្គជំនុំជម្រះសាលាដំបូងនៅតែព្យាយាមអនុវត្តតាមការព្យាករណ៍គ្រោងការសំខាន់បច្ចុប្បន្ន ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះកត់សម្គាល់ថា វាមានភាពចាំបាច់ក្នុងការពិនិត្យមើលស្ថានភាពឡើងវិញនៅចុងខែតុលា ឆ្នាំ២០១៦ ផ្អែកលើមូលដ្ឋាននៃស្ថានភាពសវនាការដែលអាចមានជាក់ស្តែងនាពេលនោះ។ វាច្បាស់ណាស់ថា មុនពេលនោះ ទំនងជាមានកត្តាជាច្រើនប៉ះពាល់បន្ថែមទៀតលើគ្រោងការនេះ។ ឧទាហរណ៍ ភាគីទំនងជានឹងបន្តស្នើសុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ឬការកោះហៅសាក្សីបន្ថែម ជាពិសេសដោយផ្អែកលើមូលដ្ឋានថា ភ័ស្តុតាងបែបនោះជាភ័ស្តុតាងដោះបន្ទុកសម្រាប់ជនជាប់ចោទ។ សំណើសុំស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែម ដែលបច្ចុប្បន្ននេះកំពុងស្ថិតនៅចំពោះមុខអង្គជំនុំជម្រះ នឹងចាំបាច់នាំឱ្យមានការបន្ថែមរយៈពេលសវនាការ ប្រសិនបើត្រូវបានទទួលយកទាំងស្រុង ឬដោយផ្នែក។ សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ អាចមានផលប៉ះពាល់សំខាន់លើច្បាប់ និងអង្គហេតុដែលអាចអនុវត្តចំពោះសំណុំរឿង០០២/០២ ដែលអាចនាំឱ្យមានសំណើសុំពន្យារពេលបន្ថែមទៀតពីភាគីនានា ដើម្បីពិចារណាលើការជាប់ពាក់ព័ន្ធទាំងអស់នេះ។

៤២. ការដាក់បង្ហាញបន្ថែមទៀតពីសំណុំរឿង ០០៣ និង ០០៤ ក៏អាចប្រមើលដឹងជាមុនផងដែរ និងអាចចាំបាច់នាំឱ្យមានការពន្យារពេលបន្ថែមទៀត។ ក្នុងន័យនេះ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ភាគច្រើននៃកំណត់ហេតុស្តាប់ចម្លើយដែលដាក់ពីសំណុំរឿង ០០៣ និង ០០៤ ដែលខ្លួនមាននាពេលបច្ចុប្បន្ននេះ ត្រូវបានដាក់បង្ហាញទៅក្នុងសំណុំរឿង ០០២/០២ រួចហើយ ហើយដូច្នេះការពន្យារពេលនាពេលខាងមុខដែលបណ្តាលមកពីការដាក់បង្ហាញឯកសារបន្ថែម ទំនងជាមិនច្រើនដូចក្នុងឆ្នាំ២០១៥ នោះទេ។ អង្គជំនុំជម្រះសាលាដំបូងក៏បានចាត់វិធានការដាក់កម្រិតបន្ថែមទៀតទៅលើដំណើរការដាក់បង្ហាញនេះ ដោយប្រកាសថាសហព្រះរាជអាជ្ញាមានកាតព្វកិច្ចជាបន្តបន្ទាប់ក្នុងការដាក់បង្ហាញទៅកាន់ភាគីការពារក្តីនូវភ័ស្តុតាងដោះបន្ទុក ដែលមាននៅក្នុងសម្ភារៈណាមួយដែលបានដឹងដោយពិតប្រាកដថា អាចបង្ហាញពីភាពគ្មានទោស ឬជួយសម្រាលពិរុទ្ធភាពរបស់ជនជាប់ចោទ ឬប៉ះពាល់ដល់ភាពអាចជឿជាក់បាននៃភ័ស្តុតាងដាក់បន្ទុក ហើយបានបង្គាប់ *ជាអាទិ៍* ឱ្យសហព្រះ

រាជអាជ្ញាស្វែងរកការអនុញ្ញាត ត្រឹមថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៦ យ៉ាងយូរ ឱ្យទទួលយកសម្ភារៈណាមួយក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលបានដាក់បង្ហាញមកទល់កាលបរិច្ឆេទនេះ ដាក់ក្នុងសំណុំរឿង ០០២/០២ ហើយដែលសហព្រះរាជអាជ្ញាមានបំណងពឹងផ្អែកលើ។ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់បន្ថែមទៀតទៅភាគីថា សំណើណាមួយសុំការអនុញ្ញាតទទួលយកភ័ស្តុតាងថ្មីក្នុងសំណុំរឿង ០០២/០២ ត្រូវដាក់នៅ ឬមុនថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦។

៤៣. កត្តាផ្សេងទៀត ដែលពាក់ព័ន្ធជាសក្តានុពលទៅនឹងរយៈពេលដែលបានស្មានទុកនៃការជំនុំជម្រះដែលអាចកើតមាននាពេលអនាគត រួមមានការប្រែប្រួលស្ថានភាពសុខភាពរបស់ជនជាប់ចោទ ដែលបង្កើតឱ្យមានតម្រូវការកាត់បន្ថយចំនួនថ្ងៃធ្វើសវនាការក្នុងសប្តាហ៍ និង/ឬ រយៈពេលនៃថ្ងៃសវនាការនីមួយៗ ក៏ដូចជាលទ្ធភាពអាចចូលរួមបានរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសាលាដំបូងកំពុងតាមដានស្ថានភាពសុខភាពរបស់ជនជាប់ចោទតាមករណីជាក់ស្តែង។ អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងអ្នកជំនាញវេជ្ជសាស្ត្រដើម្បីធ្វើការវាយតម្លៃផ្នែកផ្លូវកាយ និងផ្នែកចិត្តសាស្ត្ររបស់ជនជាប់ចោទ និងវាយតម្លៃលើសម្បទារបស់ពួកគេក្នុងការបន្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ ការពិនិត្យលើសម្បទានេះបច្ចុប្បន្នគ្រោងនឹងធ្វើឡើងនៅចុងខែកក្កដា ឆ្នាំ២០១៦។

៤៤. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមទៀត អំពីក្តីកង្វល់របស់ខ្លួនទៅការិយាល័យរដ្ឋបាលទាក់ទងនឹងការបកប្រែភាសាផ្ទាល់មាត់ និងការបកប្រែឯកសារ និងការពន្យារពេលដែលអាចមាន ប្រសិនបើកង្វល់ទាំងនេះមិនត្រូវបានដោះស្រាយ។ ការិយាល័យរដ្ឋបាលបានចាត់វិធានការដោះស្រាយបញ្ហានេះ និងបន្តត្រួតពិនិត្យបញ្ហានេះតាមករណីជាក់ស្តែងនីមួយៗ។

### ខ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុក្នុងសំណុំរឿង០០២

៤៥. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ អង្គជំនុំជម្រះតុលាការកំពូលប្រកាសផ្អាកដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទចោទដែលនៅសល់ ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ និង ០០២/០២ ដោយរង់ចាំសេចក្តីសម្រេចសមស្របរបស់អង្គជំនុំជម្រះសាលាដំបូង[8]។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងម្តងទៀតថា អង្គជំនុំជម្រះសាលាដំបូងមានករណីកិច្ចកាត់សេចក្តី ឬចេញសេចក្តីសម្រេចទៅលើបទចោទដែលនៅសល់ក្នុងសំណុំរឿង០០២ អនុលោមតាមក្រមខណ្ឌគតិយុត្តិ និងជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តទៅតាមករណីកិច្ចនេះ។ មកដល់ពេលនេះ អង្គជំនុំជម្រះពុំទាន់បានទទួលសំណើណាមួយទាក់ទិននឹងបញ្ហានេះទេ។ បញ្ហានេះនៅតែស្ថិតក្នុងការពិចារណាដដែល។

### គ. សំណុំរឿង០០៣ និង សំណុំរឿង០០៤

៤៦. លុះត្រាតែមានសេចក្តីសម្រេចថាតើ សំណុំរឿង០០៣ និង/ឬ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាចធ្វើការស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ការជំនុំជម្រះក្តីទាំងនេះបាន។ ការវាយតម្លៃលើពេលវេលាដែលតម្រូវ អាចផ្អែកទៅលើចំនួនចុងចោទ ក៏ដូចជាចំនួន និងភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទ និងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

៤៧. ដើម្បីធ្វើការប៉ាន់ស្មានអំពីរយៈពេលសម្រាប់ដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ត្រូវតែញែកឲ្យបានច្បាស់អំពីដំណាក់កាលបណ្តឹងសាទុក្ខសំខាន់ៗ ដូចតទៅ ៖ ដំណាក់កាលទីមួយ គឺត្រូវការពេលវេលាសម្រាប់ដាក់សារណារបស់ភាគីទាំងអស់។ អនុលោមតាមវិធានផ្ទៃក្នុង ភាគីត្រូវដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ

[8] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើការនីតិវិធីបន្ថែមនៃសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1/13 ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤។

ក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងករណីដែលមានបណ្តឹងសាទុក្ខដោយភាគីណាមួយ ភាគីដទៃទៀតមានរយៈពេលបន្ថែម១៥ថ្ងៃទៀត ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ។ វិធានផ្ទៃក្នុងចែងថាម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់ជូនសារណាបណ្តឹងសាទុក្ខក្នុងរយៈពេល៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្តឹងសាទុក្ខ។ ភាគីនឹងមានរយៈពេល១០ថ្ងៃក្នុងការដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ភាគីដទៃទៀត។ ប៉ុន្តែកាលពីពេលកន្លងទៅ អង្គជំនុំជម្រះបានផ្តល់ជូនរយៈពេលបន្ថែមសមរម្យសម្រាប់ដាក់ចម្លើយតប។ ក្នុងអំឡុងពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងស្រាវជ្រាវទៅលើបញ្ហាច្បាប់ និងអង្គហេតុដែលពាក់ព័ន្ធ ដើម្បីរៀបចំខ្លួនពេញលេញសម្រាប់សវនាការលើបណ្តឹងសាទុក្ខដែលជាដំណាក់កាលទីពីរ។ ស្ថិតក្នុងលក្ខខណ្ឌជាក់លាក់ ភាគីក៏មានសិទ្ធិស្នើសុំស្តាប់សវនាការលើភ័ស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ ដែលអាចតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលរៀបចំកាលវិភាគសវនាការលើភ័ស្តុតាង។ សវនាការលើបណ្តឹងសាទុក្ខអាចត្រូវបានបង្គាប់ នៅពេលណាភាគីបានដាក់សារណាទាំងអស់របស់ខ្លួន និងពិនិត្យដោយអង្គជំនុំជម្រះតុលាការកំពូលរួចហើយសិន ហើយសំណើណាមួយស្នើសុំភ័ស្តុតាងបន្ថែមត្រូវបានសម្រេច។ ដំណាក់កាលទីបី គឺការពិភាក្សាសម្រេចក្រោយពេលសវនាការនោះ និងការរៀបចំចេញសាលដីកាលើបណ្តឹងសាទុក្ខ។

### ក. សំណុំរឿង០០២/០១

៤៨. ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួននៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ និងសារណាបណ្តឹងសាទុក្ខរបស់ខ្លួននៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ដោយមូលដ្ឋានបណ្តឹងសាទុក្ខរបស់ខ្លួនមានចំនួន ២២៣ សម្រាប់ នួន ជា និង ១៥៨ សម្រាប់ ខៀវ សំផន ដែលគ្របដណ្តប់លើស្ទើរតែការរកឃើញទាំងអស់ក្នុងសាលក្រមសំណុំរឿង ០០២/០១ ព្រមទាំងលើសេចក្តីសម្រេចជាច្រើនរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនអនុញ្ញាតបើកផ្លូវប្តឹងសាទុក្ខភ្លាមៗ រហូតទាល់តែចេញសាលក្រមលើអង្គសេចក្តី[9]។ លើសនេះទៀត សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដែលកំហិតត្រឹមតែការស្នើសុំការប្រកាសពីអង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងភាពអាចអនុវត្តបាននៃទម្រង់ពង្រីកបំផុតនៃសហឧក្រិដ្ឋកម្មរួម ដែលគេស្គាល់ថា “JCE III” នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ សារណាតបទៅនឹងបណ្តឹងសាទុក្ខនេះត្រូវបានដាក់ដោយសហព្រះរាជអាជ្ញានៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤។

៤៩. ការបកប្រែឯកសារជាភាសាខ្មែរនៃចម្លើយតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ត្រូវបានបញ្ចប់ក្នុងខែសីហា និងខែកក្កដា ឆ្នាំ២០១៥ តាមលំដាប់។ សវនាការលើអង្គសេចក្តីនៃបណ្តឹងសាទុក្ខនេះមិនអាចកំណត់កាលវិភាគបាននៅឡើយទេ រហូតទាល់តែសារណា និងចម្លើយតបទាំងអស់មានជាភាសាខ្មែរ និងអង់គ្លេស ឬបារាំង។ ហេតុដូច្នេះ កត្តាមួយផ្សេងទៀតដែលកំពុងប៉ះពាល់យ៉ាងសំខាន់ដល់រយៈពេលនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខគឺពិតជាអាស្រ័យលើលទ្ធភាពនៃការបកប្រែសារណាបណ្តឹងសាទុក្ខ ជាពិសេសពីភាសាអង់គ្លេសទៅភាសាខ្មែរ។

៥០. បន្ថែមលើការដាក់ឯកសារសំខាន់ៗលើបណ្តឹងសាទុក្ខ អង្គហេតុដែលថាមេធាវីការពារក្តី នួន ជា បានអនុវត្តសិទ្ធិនីតិវិធីយ៉ាងទូលំទូលាយដែលគាត់មាន និងបានដាក់ញត្តិដាច់ដោយឡែកចំនួនប្រាំមួយ ស្នើសុំភ័ស្តុតាងបន្ថែមនៅដំណាក់កាលបណ្តឹងសាទុក្ខ ចាប់តាំងពីការចេញសាលក្រមសំណុំរឿង ០០២/០១ ក៏បានប៉ះពាល់ផងដែរលើតារាងកំណត់ពេលវេលាសម្រាប់បណ្តឹងសាទុក្ខ។ ញត្តិទាំងអស់នេះ ដែលញត្តិចុងក្រោយបានដាក់នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ភាគច្រើនជាលទ្ធផលមកពីការដាក់បង្ហាញភ័ស្តុតាងជាបន្តបន្ទាប់ ដែលត្រូវបាន

---

[9] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។

ធ្វើនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងមកពីសវនាការជាបន្តបន្ទាប់លើភ័ស្តុតាងក្នុងសំណុំរឿង០០២/០២ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ជាលទ្ធផលនៃសំណើស្នើសុំភ័ស្តុតាងបន្ថែមទាំងអស់នេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេច *ជាអាទិ៍* ឱ្យដាក់ចេញនូវការស៊ើបអង្កេតបន្ថែមដ៏មានកម្រិត ក៏ដូចជាក្នុងការកោះហៅសាក្សីបីរូបនៅពេលបណ្តឹងសាទុក្ខ។ សវនាការទាក់ទងនឹងសាក្សីទាំងបីនេះត្រូវបានធ្វើឡើងពីថ្ងៃទី២ ដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥។ ការស៊ើបអង្កេតបន្ថែមត្រូវបានបិទបញ្ចប់នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្តីសម្រេចលើសំណើសុំភ័ស្តុតាងបន្ថែមទាំងអស់ដែលនៅសេសសល់។

៥១. បញ្ហាលំបាកដែលមិនអាចប្រមើលដឹងជាមុនបានកើតឡើងនៅសវនាការបណ្តឹងសាទុក្ខ ដែលអង្គជំនុំជម្រះតុលាការកំពូលបានគ្រោងធ្វើពីថ្ងៃទី១៧ ដល់១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលគ្មានជម្រើសអ្វីក្រៅពីផ្អាកសវនាការនៅថ្ងៃដំបូង។ មូលហេតុដោយសារមិនមានតំណាងផ្នែកច្បាប់ត្រឹមត្រូវសម្រាប់ នួន ជា ដោយសារតែមេធាវីដែលត្រូវបានតែងតាំងសម្រាប់ នួន ជា ដោយអះអាងថាអនុវត្តតាមការណែនាំរបស់ជនជាប់ចោទ បានពហិការមិនចូលរួមសវនាការ ដែលខកខានមិនបានចូលរួមពេញលេញក្នុងវគ្គសវនាការ។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយបញ្ហានេះ ដោយតែងតាំងមេធាវីប្រចាំការសម្រាប់ នួន ជា ដើម្បីធានាថាកិច្ចដំណើរការនីតិវិធីអាចបន្តដោយគ្មានការរាំងស្ទះ បើទោះជាមានការប្រព្រឹត្តិណាមួយនាពេលខាងមុខរបស់មេធាវីការពារក្តី នួន ជា បច្ចុប្បន្នក្តី។ បន្ទាប់ពីការតែងតាំងមេធាវីប្រចាំការនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ និងបន្ទាប់ពីពិចារណាលើតម្រវការផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់គាត់ត្រៀមរៀបចំនោះ អង្គជំនុំជម្រះតុលាការកំពូលបានគ្រោងបន្តសវនាការបណ្តឹងសាទុក្ខឡើងវិញនៅថ្ងៃទី១៦-១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលបន្ទាប់មកអង្គជំនុំជម្រះតុលាការកំពូលបានចាប់ផ្តើមការប្រជុំពិភាក្សាសម្រេច និងធ្វើសេចក្តីព្រាងសាលដីកា។

៥២. ការកត់សម្គាល់ជាក់លាក់ គប្បីត្រូវបានធ្វើឡើងចំពោះកាលៈទេសៈពិសេសរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការដោះស្រាយសេចក្តីសម្រេចជាច្រើន ភាគច្រើនផ្នែកនីតិវិធី ដែលបានធ្វើឡើងក្នុងអំឡុងពេលកិច្ចដំណើរការជំនុំជម្រះ ដែលអាចប្តឹងសាទុក្ខបានតែក្រោយពេលចេញសាលក្រមសាលាដំបូងប៉ុណ្ណោះ។ ចំណុចនេះខុសពីស្ថានភាពនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ឬនៅសាលាក្តី *មិនអចិន្ត្រៃយ៍*នានា ដែលអាចស្នើសុំដាក់បណ្តឹងសាទុក្ខបន្ទាន់បង្ខំចំពោះសេចក្តីសម្រេចបែបអស់ទាំងនោះ ពោលគឺ ខណៈពេលកំពុងធ្វើការជំនុំជម្រះ ដើម្បីដោះស្រាយបញ្ហាចម្រូងចម្រាសនានាដែលកើតមានឡើង។ យ៉ាងណាមិញ យោងតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. យុត្តាធិការបណ្តឹងសាទុក្ខក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះគឺមានកម្រិតតិចតួចបំផុត។ ហេតុដូច្នេះ បន្ទាប់ពីការវិភាគលើសារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២ វាបង្ហាញយ៉ាងច្បាស់ថាពេលនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវលះបង់ពេលរបស់ខ្លួនប្រមាណ ៥០% ដើម្បីពិនិត្យបញ្ហានានា ដែលនៅ ICC ឬសាលាក្តី *មិនអចិន្ត្រៃយ៍* អាចបានដោះស្រាយតាំងពីមុនបណ្តឹងសាទុក្ខម្លេះ។

៥៣. ដោយពិចារណាលើកត្តាទាំងអស់នេះ និងបទពិសោធន៍ពីតុលាការ និងសាលាក្តីអន្តរជាតិ និងអន្តរជាតូបនីយកម្មផ្សេងទៀត ដែលសំណុំរឿងមានទំហំនិងភាពស្មុគស្មាញប្រហាក់ប្រហែលគ្នា អង្គជំនុំជម្រះតុលាការកំពូលប្រមើលទុកជាមុនថា ការចេញសាលដីកានឹងកើតឡើងនៅក្នុងត្រីមាសទីបី ឆ្នាំ២០១៦។ ខែបន្ទាប់នឹងមានការបញ្ចប់ការប្រជុំពិភាក្សាសម្រេច និងការធ្វើសេចក្តីព្រាងសាលដីកា។ កាលបរិច្ឆេទប្រកាសសាលដីកានឹងប្រកាសរយៈពេលពីរបីសប្តាហ៍មុន។

### ខ. សំណុំរឿង ០០២/០២

៥៤. សម្រាប់សំណុំរឿង០០២/០២ ដោយផ្អែកលើការព្យាករណ៍បច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការជំនុំជម្រះដំណាក់កាលទីពីរទំនងជានឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាច្រើនដូចជាការជំនុំជម្រះដំណាក់កាលទីមួយនោះ អង្គជំនុំជម្រះតុលាការកំពូលក៏ព្យាករស្រដៀងគ្នានេះដែរនៅពេលនេះដែលថាបណ្តឹងសាទុក្ខ(ទាំងឡាយ)ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង០០២/០២ នឹង

មានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាច្រើន ដូចគ្នានឹងបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង០០២/០១ ហើយកត្តានានា ដូចជាសំណើសុំពន្យារពេលក្នុងការដាក់សារណា ឬញត្តិ ដើម្បីស្នើដាក់ជូនភស្តុតាងបន្ថែម អាចប៉ះពាល់ដល់រយៈពេលនៃដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។ ទំហំការងារបែបនេះនឹងត្រូវការគិតបញ្ចូលទៅក្នុងការរៀបចំផែនការក្រោយពេលមានការដាក់បណ្តឹងសាទុក្ខ។

៥៥. ជាងនេះទៅទៀត រហូតទាល់តែសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ ត្រូវបានចេញ ទើបអាចមានបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តីនោះ ដែលត្រូវតែចេញសេចក្តីសម្រេចក្នុងរយៈពេលកំណត់បីខែ (កាលបរិច្ឆេទកំណត់នេះអាចពន្យារពេលទៅបួនខែ ក្នុងកាលៈទេសៈពិសេស)។

### គ. សំណុំរឿង ០០៣ និង សំណុំរឿង ០០៤

៥៦. ប្រសិនបើសំណុំរឿង០០៣ និង/ឬ ០០៤ បន្តទៅជំនុំជម្រះ បណ្តឹងឧទ្ធរណ៍ភ្លាមៗ ក៏ដូចជាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ទំនងជាកើតមាន។ យ៉ាងណាក៏ដោយ ដោយសារតែបច្ចុប្បន្នមិនដឹងថារឿងក្តីមួយណា ប្រសិនបើមាន នឹងបន្តទៅជំនុំជម្រះ និងផ្អែកលើបទចោទមួយណានោះ បច្ចុប្បន្នគេមិនអាចផ្តល់ការប៉ាន់ស្មានសម្រាប់ពេលវេលាដែលត្រូវការ ក្នុងការធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយដែលកើតមាននោះទេ។ យ៉ាងណាមិញ គួរកត់សម្គាល់ថា បណ្តឹងឧទ្ធរណ៍ភ្លាមៗអាចកើតឡើងពីសំណុំរឿង ០០៣ និង ០០៤ ភ្លាមៗបន្ទាប់ពីសំណុំរឿងណាមួយក្នុងចំណោមសំណុំរឿងទាំងនេះឈានទៅដល់ដំណាក់កាលជំនុំជម្រះ។

## VI. សេចក្តីសន្និដ្ឋាន

៥៧. សម្រាប់ឆ្នាំ ២០១៦ យើងរំពឹងថានឹងសម្រេចបាននូវគ្រោងការសំខាន់ៗចំនួនពីរ ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ គឺ៖ (i) ការចេញសាលដីកាក្នុងសំណុំរឿង ០០២/០១ និង (ii) ការបញ្ចប់សវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០២។ ចំពោះសំណុំរឿង ០០៣ និង ០០៤ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការសំខាន់ៗចំនួនពីរគឺ៖ (i) ការជូនដំណឹងអំពីការបិទបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ (ii) ការជូនដំណឹងអំពីការបិទបញ្ចប់កិច្ចស៊ើបសួរសម្រាប់ការចោទប្រកាន់ដែលនៅសល់ក្នុងសំណុំរឿង ០០៤ ពាក់ព័ន្ធនឹង អោ អាន។

៥៨. សម្រាប់ឆ្នាំ២០១៧ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនពីរ ក្នុងសំណុំរឿង០០២/០២ ពោលគឺ៖ (i) ការបញ្ចប់សេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល និង (ii) ការចេញសាលក្រម។ ក្នុងសំណុំរឿង ០០៣ និង ០០៤ រំពឹងថានឹងសម្រេចបានគ្រោងការសំខាន់ចំនួនបួនបន្ថែមទៀតគឺ៖ (i) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី (ii) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (iii) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម និង ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ប្រឆាំងនឹង អោ អាន និង យឹម ទិត្យ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។ (iv) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០១ ជាមួយនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។ ក្នុងករណីដែលសំណុំរឿងណាមួយ ត្រូវបានបញ្ជូនទៅជំនុំជម្រះទាំងមូល ឬដោយផ្នែក ការព្យាករណ៍ទុកនូវតារាងកំណត់ពេលវេលាក្នុងសំណុំរឿងទាំងនេះ គឺអាចយកមកវាយតម្លៃបាន។

៥៩. ក្នុងអំឡុងឆ្នាំ២០១៨ រំពឹងថាគម្រោងសំខាន់មួយនឹងសម្រេចបានក្នុងសំណុំរឿង ០០២/០២ គឺកាលបរិច្ឆេទកំណត់សម្រាប់បណ្តឹងសាទុក្ខណាមួយប្រឆាំងនឹងសាលក្រម។ អង្គជំនុំជម្រះតុលាការកំពូលនឹងជាប់រវល់ធ្វើសវនាការបណ្តឹងសាទុក្ខ និងការពិភាក្សាសម្រេច ក្នុងករណីដែលមានបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០២។ ទាក់ទងនឹងសំណុំរឿង ០០៤ គ្រោងការមួយរំពឹងថានឹងសម្រេចបានគឺ៖ (i) ការ

សម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤ ទាក់ទងនឹង យឹម ទិត្យ ជាមួយនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី ។ ក្នុងករណីដែលរឿងក្តីត្រូវបញ្ជូនទៅជំនុំជម្រះ ទាំងមូល ឬដោយផ្នែក ការព្យាករណ៍ទុកនូវតារាងកំណត់ពេលវេលាក្នុងសំណុំរឿងទាំងនេះ គឺអាចយកមកវាយតម្លៃបាន។

៦០. សម្រាប់ឆ្នាំ២០១៩ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការសំខាន់ចំនួនមួយគឺ ការចេញសាលដីកាលើសំណុំរឿង០០២/០២។

៦១. ការស្មានទុកនូវគ្រោងការសំខាន់ៗនានាដែលរៀបរាប់ខាងលើនេះ មានសង្ខេបជូនក្នុងតារាងដែលភ្ជាប់ជាមួយនឹងផែនការនេះស្រាប់។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានគ្រោងការសំខាន់ៗ




ប្រសិនបើបំបែក

(ដ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត។ ពេលវេលាកំណត់អាស្រ័យទៅលើថាតើ សំណុំរឿងនឹងត្រូវបានបំបែកឬទេ។
(ឋ) ដីកាដំណោះស្រាយ កសចស។ ពេលវេលាកំណត់អាស្រ័យទៅលើ សំណុំរឿងនឹងត្រូវបានបំបែកឬទេ។
(ឌ) សេចក្តីសម្រេចរបស់ អបជ ទៅលើដីកាដំណោះស្រាយ។